Khmer | ភាសាខ្មែរ

GOVERNMENT OF WESTERN AUSTRALIA

**Roll up for WA**

COVID-19 Vaccination

# ទទួលបានការពិត អំពីវ៉ាក់សាំង




វាជាការធម្មតាទេក្នុងការមានសំណួរនានាទាក់ទងនឹងរឿងថ្មីៗ។ ស្វែងយល់ពីអ្វីដែលពិត និងអ្វីដែលមិនពិតអំពីវ៉ាក់សាំង COVID-19។ យើងត្រូវការរួមគ្នាបង្កើតទំនុកចិត្តលើវ៉ាក់សាំង ពីព្រោះយើងម្នាក់ៗ និងរាល់មនុស្សដែលបានចាក់វ៉ាក់សាំងហើយ ជួយយើងឱ្យឆ្លងផុតពីជំងឺរាតត្បាត។

## ការពិត

### វ៉ាក់សាំងមានសុវត្ថិភាព

មនុស្សជាច្រើននៅជុំវិញពិភពលោក បានធ្វើការរួមគ្នាដើម្បីបង្កើតវ៉ាក់សាំង COVID-19 ចែករំលែកប្រាក់ និងអ្នកវិទ្យាសាស្ត្រ ដើម្បីផលិតវាក្នុងរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ ដោយមិនរំលងជំហានណាមួយឡើយ។ វ៉ាក់សាំងត្រូវបានអនុញ្ញាតឱ្យប្រើនៅក្នុងប្រទេសអូស្ត្រាលីតែប៉ុណ្ណោះ បន្ទាប់ពីបានធ្វើតេស្ត ហើយរកឃើញថាមានសុវត្ថិភាព និងប្រសិទ្ធភាព។ វ៉ាក់សាំងទាំងអស់ត្រូវបានបន្តធ្វើតេស្តពិនិត្យគុណភាព និងតាមដានរកមើលសុវត្ថិភាព។

### វ៉ាក់សាំង COVID-19 មិនមានផ្ទុកវីរុសរស់ទេ ហើយមិនអាចចម្លង COVID-19 ទៅអ្នកបានទេ

វ៉ាក់សាំងទាំងនេះបំពេញមុខការដូចជាមេរោគពិតៗ ហើយបង្រៀនរាងកាយរបស់អ្នកពីវិធីការពារខ្លួនវា។ នេះនឹងជួយបញ្ឈប់អ្នកពីការឈឺធ្ងន់ធ្ងរ ហើយទៅមន្ទីរពេទ្យ ឬស៊ូម្បីតែស្លាប់ផងដែរ។

### មីក្រូឈីបនឹងមិនអាចស៊កចូលតាមម្ជុលវ៉ាក់សាំងបានទេ

ជំនឿមិនត្រឹមត្រូវនេះផ្អែកលើវីដេអូក្លែងក្លាយមួយ ដែលកំពុងផ្សព្វផ្សាយបន្តគ្នានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

## ជំនឿមិនត្រឹមត្រូវ

- ✗ វ៉ាក់សាំង COVID-19 ត្រូវបានអនុម័តយ៉ាងឆាប់រហ័សថាមានសុវត្ថិភាព។
- ✗ វ៉ាក់សាំង COVID-19 អាចឱ្យអ្នកកើត COVID-19។
- ✗ វ៉ាក់សាំង COVID-19 មានមីក្រូឈីបដើម្បីតាមដានខ្ញុំ។

# ទទួលបានការពិតអំពីវ៉ាក់សាំង

## ការពិត

### វ៉ាក់សាំងគឺមិនគិតថ្លៃ សម្រាប់មនុស្សគ្រប់រូបនៅរដ្ឋអូស្ត្រាលីខាងលិច

នេះរួមបញ្ចូលទាំងអ្នកស្នាក់នៅបណ្តោះអាសន្ន ជនភៀសខ្លួន ជនចំណាកស្រុក និងមនុស្សដែលពុំមានទិដ្ឋាការត្រឹមត្រូវ។

### យើងស្គាល់គ្រប់ទាំងសារធាតុផ្សំដែលមាននៅក្នុងវ៉ាក់សាំង

វ៉ាក់សាំងភាគច្រើនមានសារធាតុទឹក អំបិល ស្ករ និងខ្លាញ់។ ពុំមានក្រាហ្វិន អុកស៊ីត សារធាតុគ្លុយទីន (gluten), ស៊ុត ស្រូវសាលី ពិសឃ្មុំ ជ័រកៅស៊ូ ឬផលិតផលធ្វើពីសត្វ នៅក្នុងវ៉ាក់សាំងទេ។ ក្រុមប្រឹក្សា Fatwa អូស្ត្រាលី បានគាំទ្រវ៉ាក់សាំងទាំងនេះ ថាផលិតផលហាឡាល (Halal)។

### អ្នកអាចទទួលបានវ៉ាក់សាំង COVID-19 ទោះបីជាអ្នកមិនមានប័ណ្ណមេឌីឃែរក៏ដោយ

អ្នកត្រូវបង្ហាញអត្តសញ្ញាណសម្គាល់ខ្លួនរបស់អ្នក នៅពេលណាត់ជួបរបស់អ្នក ដូច្នេះសូមយកឯកសារមួយដែលមានឈ្មោះរបស់អ្នកមកជាមួយ ដូចជា ប័ណ្ណបើកបរ លិខិត ឬវិក្កយបត្រ។

### ការទទួលវ៉ាក់សាំង COVID-19 មិនធ្វើឱ្យអ្នកទៅជាមេដែកឆក់ - នៅគ្រប់កន្លែងលើរាងកាយរបស់អ្នកនោះទេ

វ៉ាក់សាំង COVID-19 មិនមានសារធាតុផ្សំមានមេដែកឆក់ ដែលអាចធ្វើដូចនេះបានទេ។ អ្នកនឹងត្រូវការលោហៈធាតុជាច្រើន ដើម្បីទាក់ទាញមេដែកឆក់។ ជាឧទាហរណ៍ មនុស្សប្រើថ្នាំវីតាមីនចម្រុះ ដែលជារឿយៗមានផ្ទុកជាតិដែក។ នេះមិនធ្វើឱ្យពួកគេទៅជាមេដែកឆក់នោះទេ ពីព្រោះជាតិដែកទាំងនេះ រាវណាស់ ហើយរាលដាលពេញរាងកាយរបស់អ្នក។

### វ៉ាក់សាំង COVID-19 មិនប៉ះពាល់ដល់ការមានកូនទេ

វ៉ាក់សាំងមិនប៉ះពាល់ដល់សមត្ថភាពរបស់អ្នក ក្នុងការមានកូននៅពេលនេះ ឬទៅអនាគតទេ។ ជាការណែនាំយ៉ាងខ្លាំងផងដែរថា ស្ត្រីមានផ្ទៃពោះត្រូវចាក់វ៉ាក់សាំង COVID-19 ដើម្បីការពារខ្លួនពួកគេ និងការពារទារករបស់ពួកគេ។

## ជំនឿមិនត្រឹមត្រូវ

- ✗ វាត្រូវចំណាយប្រាក់ដើម្បីចាក់វ៉ាក់សាំង COVID-19។
- ✗ យើងមិនដឹងថាមានអ្វីខ្លះផ្ទុកក្នុងវ៉ាក់សាំងទាំងនេះទេ។
- ✗ អ្នកត្រូវមានប័ណ្ណមេឌីឃែរមានសុពលភាព ដើម្បីទទួលបានវ៉ាក់សាំង COVID-19។
- ✗ វ៉ាក់សាំង COVID-19 អាចបង្កើតជាមេដែកឆក់មួយ ជាប់នឹងដៃរបស់អ្នក។
- ✗ វ៉ាក់សាំង COVID-19 ប៉ះពាល់ដល់ការមានកូន។

**ចុះឈ្មោះ និងកក់ការចាក់វ៉ាក់សាំង COVID-19 របស់អ្នក**

**rollupforwa.com.au**

**13COVID (13 26843)**

សូមចុច * សម្រាប់អ្នកបកប្រែផ្ទាល់មាត់